ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ:២៤៦៧ សសល/ប្រកាស

ប្រកាស
ស្តីពី
ការគ្រប់គ្រងការនាំចូល ការនាំចេញ និងការចែកចាយ វត្ថុធាតុដើម សារធាតុគីមីផ្សំឱសថញៀន និងឱសថមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទឬឱសថព្យាបាលជំងឺផ្លូវចិត្ត

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣៧ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ ៦៧អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

សម្រេច

ផ្នែកទី១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ប្រកាសនេះមានគោលបំណងគ្រប់គ្រង ការនាំចូល ការនាំចេញ ការចែកចាយ វត្ថុធាតុដើម សារធាតុគីមីផ្សំឱសថញៀន និងឱសថមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ឬឱសថព្យាបាលជំងឺផ្លូវចិត្ត ដើម្បីធានាបាននូវសុវត្ថិភាព គុណភាព និងប្រសិទ្ធភាព។

ប្រការ ២.-

ប្រកាសនេះមានគោលដៅកំណត់ពីវិធានក្នុងការគ្រប់គ្រង ការនាំចូល ការនាំចេញ និងការចែកចាយវត្ថុធាតុដើម សារធាតុគីមីផ្សំ ឱសថញៀន និងឱសថមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទឬឱសថព្យាបាលជំងឺផ្លូវចិត្ត។

ទីស្តីការក្រសួងសុខាភិបាល ជីឡូតិ៍លេខ ៨០ ថ្វីសម្តេច ប៉ែន នុត (២៨៩) រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ប្រការ ៣.-

ប្រកាសនេះមានវិសាលភាពគ្របដណ្តប់ទៅលើគ្រឹះស្ថានផលិតវត្ថុធាតុដើម គ្រឹះស្ថានផលិតឱសថ គ្រឹះស្ថានអាហារ័ណ នីហារ័ណឱសថ គ្រឹះស្ថានលក់ដុំឱសថ ឱសថស្ថាន មូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា។

ផ្នែកទី២
បែបបទ នីតិវិធី និងលក្ខខណ្ឌនៃការអនុញ្ញាត

ប្រការ ៤.-

ការនាំចូល ការនាំចេញវត្ថុធាតុដើម សារធាតុគីមីផ្សំឱសថញៀន និងឱសថមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ឬឱសថព្យាបាលជំងឺផ្លូវចិត្ត ត្រូវមានការអនុញ្ញាតពីក្រសួងសុខាភិបាល។

ប្រការ ៥.-

ការនាំចូលឱសថញៀន និងឱសថដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ឬឱសថព្យាបាលជំងឺផ្លូវចិត្តត្រូវបំពេញសំណុំលិខិតដូចខាងក្រោម៖

១- ពាក្យស្នើសុំនាំចូល (មានគំរូ)	ចំនួន	០២ច្បាប់
២- តារាងបញ្ជីឱសថនាំចូល	ចំនួន	០២ច្បាប់
៣- វិក័យប័ត្រប្រូហ្វ័រម៉ា (Proforma Invoice)	ចំនួន	០២ច្បាប់
៤- លិខិតអនុញ្ញាតនាំចូលលើកមុន (ករណីធ្លាប់នាំចូល)	ចំនួន	០១ច្បាប់
៥- វិញ្ញាបនបត្របញ្ជិកាឱសថ	ចំនួន	០១ច្បាប់
៦- របាយការណ៍ចែកចាយឱសថ	ចំនួន	០១ច្បាប់
៧- របាយការណ៍ស្តីពីការចុះត្រួតពិនិត្យ	ចំនួន	០១ច្បាប់

ប្រការ ៦.-

ការនាំចេញឱសថញៀន និងឱសថដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ឬឱសថព្យាបាលជំងឺផ្លូវចិត្តត្រូវបំពេញសំណុំលិខិតដូចខាងក្រោម៖

១- ពាក្យស្នើសុំនាំចេញ (មានគំរូ)	ចំនួន	០២ច្បាប់
២- តារាងបញ្ជីឱសថនាំចេញ	ចំនួន	០២ច្បាប់
៣- វិក័យប័ត្រពាណិជ្ជកម្ម (Commercial Invoice)	ចំនួន	០២ច្បាប់
៤- លិខិតអនុញ្ញាតនាំចូល (ករណីនាំចូលដើម្បីនាំចេញ)	ចំនួន	០១ច្បាប់
៥- លិខិតអនុញ្ញាតពីប្រទេសនាំចូល	ចំនួន	០១ច្បាប់
៦- វិញ្ញាបនបត្របញ្ជិកាឱសថ	ចំនួន	០១ច្បាប់

ប្រការ ៧.-

ការនាំចូលវត្ថុធាតុដើម ឬសារធាតុគីមីផ្សំត្រូវបំពេញសំណុំលិខិតដូចខាងក្រោម៖

១- លិខិតស្នើសុំនាំចូល	ចំនួន	០២ច្បាប់
២- តារាងបញ្ជីវត្ថុធាតុដើម ឬសារធាតុគីមីផ្សំនាំចូល	ចំនួន	០២ច្បាប់
៣- វិក័យប័ត្រប្រូហ្វ័រម៉ា (Proforma Invoice)	ចំនួន	០២ច្បាប់
៤- រូបមន្តលំអិតនៃការផលិតវត្ថុធាតុដើម ឬសារធាតុគីមីផ្សំ	ចំនួន	០២ច្បាប់
៥- លិខិតអនុញ្ញាតនាំចូលលើកមុន	ចំនួន	០១ច្បាប់

ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

៦- វិញ្ញាបនបត្រទិដ្ឋាការឱសថត្រូវផលិត ឬពាណិជ្ជនាម
(លើកលែងករណីផលិតសាកល្បង) ចំនួន ០១ច្បាប់
៧- របាយការណ៍ផលិត និងចែកចាយវត្ថុធាតុដើម
សារធាតុគីមីផ្សំ ឬឱសថ(លើកលែងករណីផលិតសាកល្បង) ចំនួន ០១ច្បាប់
៨- របាយការណ៍ស្តីពីការចុះត្រួតពិនិត្យ ចំនួន ០១ច្បាប់

ប្រការ ៨.-

ការនាំចេញវត្ថុធាតុដើម ឬសារធាតុគីមីផ្សំត្រូវបំពេញសំណុំលិខិតដូចខាងក្រោម៖
១- លិខិតស្នើសុំនាំចេញ ចំនួន ០២ច្បាប់
២- តារាងបញ្ជីវត្ថុធាតុដើម សារធាតុគីមីផ្សំនាំចេញ ចំនួន ០២ច្បាប់
៣- វិក័យប័ត្រពាណិជ្ជកម្ម (Commercial Invoice) ចំនួន ០២ច្បាប់
៤- លិខិតអនុញ្ញាតនាំចូល (ករណីនាំចូលដើម្បីនាំចេញ) ចំនួន ០១ច្បាប់
៥- លិខិតអនុញ្ញាតពីប្រទេសនាំចូល ចំនួន ០១ច្បាប់

ប្រការ ៩.-

លិខិតអនុញ្ញាតសម្រាប់នាំចូល នាំចេញវត្ថុធាតុដើម សារធាតុគីមីផ្សំ ឱសថញៀន និងឱសថមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ឬឱសថព្យាបាលជំងឺផ្លូវចិត្ត មានសុពលភាពរយៈពេល ០៨(ប្រាំបី) ខែ។

ផ្នែកទី៣
ការគ្រប់គ្រងឱសថញៀន
ឱសថមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទឬឱសថព្យាបាលជំងឺផ្លូវចិត្ត

ប្រការ ១០.-

គ្រឹះស្ថានផលិតឱសថ គ្រឹះស្ថានអាហារ័ណ នីហារ័ណឱសថ ត្រូវចែកចាយឱ្យតែគ្រឹះស្ថានលក់ដុំឱសថ និងឱសថស្ថានស្របច្បាប់តែប៉ុណ្ណោះដោយរក្សាវិក័យប័ត្រចែកចាយ។ វិក័យប័ត្រចែកចាយត្រូវមានឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ របស់គ្រឹះស្ថាន និងរក្សាទុករយៈពេល ១០(ដប់) ឆ្នាំ។

ប្រការ ១១.-

គ្រឹះស្ថានផលិតវត្ថុធាតុដើមឱសថ គ្រឹះស្ថានផលិតឱសថ គ្រឹះស្ថានអាហារ័ណ នីហារ័ណឱសថត្រូវធ្វើរបាយការណ៍ស្តីពីការនាំចេញ ការនាំចូល និងការប្រើប្រាស់ ឬការចែកចាយប្រចាំខែមកនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាងនៃក្រសួងសុខាភិបាលដូចខាងក្រោម៖

១-ចំពោះគ្រឹះស្ថានផលិតឱសថ ឬគ្រឹះស្ថានផលិតវត្ថុធាតុដើមឱសថ
ក-វត្ថុធាតុដើម ឬសារធាតុគីមីផ្សំ៖
- ឈ្មោះវត្ថុធាតុដើម ឬសារធាតុគីមីផ្សំបាននាំចេញ នាំចូល
- ឈ្មោះប្រទេសនាំចូល ឬប្រទេសនាំចេញ
- ឈ្មោះ និងអាសយដ្ឋានរោងចក្រផលិត
- លេខឡុតផលិត
- រូបមន្តផលិតក្នុងមួយឡុត
- របាយការណ៍ផលិតបាន

ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

- នៅពេលវត្ថុធាតុដើម ឬសារធាតុគីមីផ្សំមកដល់គ្រឹះស្ថានផលិតឱសថ ត្រូវផ្តល់ដំណឹងមកក្រសួងសុខាភិបាល (នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង) ដើម្បីចុះត្រួតពិនិត្យជាក់ស្តែងមុននឹងយកទៅប្រើប្រាស់ ឬចែកចាយ។

ខ-ឱសថញៀន ឱសថមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទឬឱសថព្យាបាលជំងឺផ្លូវចិត្ត៖

- ឈ្មោះឱសថត្រូវនាំចេញ
- ឈ្មោះប្រទេសត្រូវនាំចេញ និងអាសយដ្ឋានអ្នកបញ្ជាទិញ
- ឈ្មោះ និងអាសយដ្ឋានរោងចក្រផលិត
- លេខឡូតិ៍ផលិត
- របាយការណ៍ចែកចាយក្នុងប្រទេសដោយមានបញ្ជាក់ឈ្មោះទីតាំងចែកចាយឱ្យបានច្បាស់លាស់ និងត្រឹមត្រូវ។

២-ចំពោះគ្រឹះស្ថានអាហរ័ណ នីហរ័ណឱសថ៖

- ឈ្មោះឱសថដែលបាននាំចូល
- ចំនួនឱសថដែលបាននាំចូលដោយផ្ទៀងផ្ទាត់ជាមួយលិខិតអនុញ្ញាតនាំចូល
- ឈ្មោះប្រទេសនាំចេញ
- ឈ្មោះរោងចក្រផលិត
- អាសយដ្ឋានរោងចក្រផលិត
- លេខឡូតិ៍ផលិត
- ថ្ងៃខែឆ្នាំផលិត និងថ្ងៃខែឆ្នាំផុតកំណត់ប្រើប្រាស់
- ពិនិត្យលើរបាយការណ៍នាំចូលលើកមុន ទិសដៅលក់ចេញ សល់នៅក្នុងស្តុកដោយមានបញ្ជាក់ច្បាស់លាស់ទីតាំងចែកចាយ
- នៅពេលឱសថមកដល់គ្រឹះស្ថានអាហរ័ណ នីហរ័ណឱសថត្រូវផ្តល់ដំណឹងមកក្រសួងសុខាភិបាល (នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង) ដើម្បីចុះត្រួតពិនិត្យជាក់ស្តែងមុននឹងយកទៅលក់ចេញ និងចែកចាយ។

ប្រការ ១២.-

ក្រុមការងារចុះត្រួតពិនិត្យឱសថញៀន និងឱសថមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ឬឱសថព្យាបាលជំងឺផ្លូវចិត្តនៃនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង មានភារកិច្ចដូចខាងក្រោម៖

- ចុះត្រួតពិនិត្យគ្រឹះស្ថានផលិតវត្ថុធាតុដើមឱសថ គ្រឹះស្ថានផលិតឱសថ គ្រឹះស្ថានអាហរ័ណ នីហរ័ណឱសថនៅពេលស្នើសុំនាំចូល នាំចេញវត្ថុធាតុដើម សារធាតុគីមីផ្សំ ឱសថញៀន និងឱសថមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទឬឱសថព្យាបាលជំងឺផ្លូវចិត្ត
- ចុះត្រួតពិនិត្យគ្រឹះស្ថានផលិតវត្ថុធាតុដើមឱសថ គ្រឹះស្ថានផលិតឱសថ គ្រឹះស្ថានអាហរ័ណ នីហរ័ណឱសថនៅពេលដែលវត្ថុធាតុដើម សារធាតុគីមីផ្សំ ឱសថញៀន និងឱសថមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទឬឱសថព្យាបាលជំងឺផ្លូវចិត្តមកដល់គ្រឹះស្ថាន
- ចុះត្រួតពិនិត្យគ្រឹះស្ថានផលិតវត្ថុធាតុដើមឱសថ គ្រឹះស្ថានផលិតឱសថ គ្រឹះស្ថានអាហរ័ណ នីហរ័ណឱសថរៀងរាល់ឆ្នាំ ឬអាចចុះត្រួតពិនិត្យបានគ្រប់ពេលក្នុងករណីចាំបាច់។

ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ប្រការ ១៣.-

ត្រូវរៀបចំទុកដាក់វត្ថុធាតុដើម សារធាតុគីមីផ្សំ ឱសថញៀន និងឱសថមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ឬឱសថព្យាបាលជំងឺផ្លូវចិត្តនៅក្នុងទូ ឬកន្លែងដាច់ដោយឡែកដែលមានសុវត្ថិភាពហើយមានចាក់សោរពីរជាន់ និងគ្រប់គ្រងដោយមនុស្សពីរនាក់ (ប្រធានឃ្លាំង និងឱសថការីទទួលបន្ទុកបច្ចេកទេស)។

ប្រការ ១៤.-

ក្រសួងសុខាភិបាលមានសិទ្ធិផ្អាកនូវរាល់ការស្នើសុំនាំចូល នាំចេញ សារធាតុគីមីផ្សំ ឱសថញៀន និងឱសថមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទឬឱសថព្យាបាលជំងឺផ្លូវចិត្តរបស់គ្រឹះស្ថានផលិតឱសថ និងគ្រឹះស្ថានអាហារណា នីហារណឱសថដែលប្រព្រឹត្តផ្ទុយនឹងច្បាប់ដែលមានជាធរមាន។

ផ្នែកទី៤
អវសានប្បញ្ញត្តិ

ប្រការ ១៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ១៦.-

នាយកឧទ្ធកាល័យក្រសួងសុខាភិបាល អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការ ប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង ប្រធាននាយកដ្ឋាន ប្រធានអង្គភាព ក្រោមឱវាទក្រសួងសុខាភិបាល ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ១១ រោច ខែផល្គុន ឆ្នាំឆ្លូវត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០២២

រ.ជ.ហ
មិន ប៊ុនហេង

កន្លែងទទួលៈ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងមហាផ្ទៃ
-អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
-រដ្ឋបាលរាជធានី ខេត្ត
-ដូចប្រការ ១៦
-ឯកសារ កាលប្បវត្តិ

ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩